វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

FAIR FINANCE CAMBODIA
A MEMBER OF FAIR FINANCE ASIA

OXFAM

# ការអនុវត្តកាតព្វកិច្ចអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម នៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា

# សេចក្តីសង្ខេបគោលនយោបាយ

## ១. សេចក្តីផ្តើម

វិស័យធនាគារ និងហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់ និងជាយន្តការមួយក្នុងការជំរុញឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ការធានាបាននូវលំហូរសាច់ប្រាក់ និងការធ្វើចរាចរណ៍រូបិយប័ណ្ណជាភារកិច្ចសំខាន់ ក្នុងការបង្កើនសកម្មភាពសេដ្ឋកិច្ចទាំងជាតិ និងទាំងប្រជាពលរដ្ឋដែលកំពុងប្រករបរចិញ្ចឹម ជីវិត។ ការកើនឡើងនូវវត្ថុមាន និងបរិមាណជាច្រើននៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាជាសក្ខីភាពបញ្ជាក់យ៉ាងច្បាស់នូវកំណើនសកម្មភាពសេដ្ឋកិច្ច ក្នុងនោះការកើនឡើងនូវគម្រោងវិនិយោគ ឬគម្រោងអភិវឌ្ឍន៍ទាំងឡាយ ដែលបានស្នើឡើងតាមគោលនយោបាយអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជា ។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងនេះជាប្រភពផ្តល់នូវទុនជាចាំបាច់សម្រាប់ការវិនិយោគនានា។ នៅក្នុងទិដ្ឋភាពសេដ្ឋកិច្ច ការផ្តល់កម្ចីទាំងនោះដល់ម្ចាស់គម្រោងអភិវឌ្ឍន៍ជាផលវិជ្ជមាន ប៉ុន្តែការព្រួយបារម្ភ និងហានិភ័យមួយចំនួនទៅដល់ធនធានបរិស្ថាន និងសង្គមពីគម្រោងដែលទទួលបានកម្ចីទាំងនោះ ជាទិដ្ឋភាពដោយឡែកដែលចាំបាច់ត្រូវធ្វើការគិតគូរឱ្យបានហ្មត់ចត់។

ស្ថានភាពប៉ះពាល់ទាំងនេះ បានបង្កឱ្យមានអរិភាពគ្នារវាងប្រជាពលរដ្ឋមូលដ្ឋាន និងគម្រោងអភិវឌ្ឍន៍។ ជាក់ស្តែងណាស់ ការខូចខាតនានាទៅលើធនធានពីសកម្មភាពរបស់គម្រោងអភិវឌ្ឍន៍ ក៏ជាការចូលរួមចំណែកដោយប្រយោលពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលបានផ្តល់កម្ចី។ ជាទូទៅមុនពេលដែលកម្ចីត្រូវបានអនុម័ត ធនាគារបានធ្វើការវាយតម្លៃ និងធ្វើរបាយការណ៍ហិរញ្ញប្បទានអំពីម្ចាស់គម្រោង (ដោយគិតគូរជាពិសេសតែទៅលើលទ្ធភាព ឬសមត្ថភាពក្នុងការសងត្រឡប់មកវិញ) ដោយមិនបានធ្វើការវាយតម្លៃ ឬពិចារណាទៅលើផលប៉ះពាល់ ដែលគម្រោងនឹងទទួលបានកម្ចីនោះ អាចបង្កជាហានិភ័យធ្ងន់ធ្ងរដល់មជ្ឈដ្ឋានជុំវិញតំបន់ដែលគម្រោងទាំងនោះតាំងនៅ។ ការខ្វះខាតនូវតម្រូវការពេញលេញអំពីផលប៉ះពាល់បរិស្ថាន និងសង្គមនេះ មិនត្រឹមតែធ្វើឱ្យខូចខាតធនធានតែប៉ុណ្ណោះទេ តែថែមទាំងអាចបង្កឱ្យគម្រោងខ្លួនឯងបរាជ័យ និងមិនអាចមានលទ្ធភាពសងត្រឡប់ទៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

តាមរយៈទិន្នន័យក្នុងរបាយការណ៍ប្រចាំឆ្នាំ (២០១៨)[1] របស់ក្រុមហ៊ុនស៊ីប៊ីស៊ី គិតត្រឹមឆ្នាំ២០១៨ ប្រជាពលរដ្ឋសរុបចំនួនប្រមាណជាង ៣លាននាក់ នៅក្នុងប្រទេសកម្ពុជាបាននឹងកំពុងមានជាប់កម្ចី ឬឥណទានពីស្ថាប័នហិរញ្ញវត្ថុ និងក្នុងទំហំទឹកប្រាក់សរុបចំនួន ២០,៨៥៤លានដុល្លារអាមេរិក។ ក្នុងចំណោមប្រជាពលរដ្ឋទាំងនោះ ស្ត្រីចំនួន ៥៧ភាគរយជាម្ចាស់កម្ចី ឬឥណទានទាំងនោះ។ ១៧ភាគរយនៃម្ចាស់កម្ចីមានទំនាក់ទំនងជាមួយស្ថាប័នហិរញ្ញវត្ថុច្រើនជាងមួយ[2]។

## ២. អត្ថបទនេះមានគោលបំណង

- បង្ហាញនូវគំលាតគោលនយោបាយ នៅក្នុង វិស័យធនាគារ និងវិស័យបរិស្ថានដែលជំរុញឱ្យមាននូវអភិបាលកិច្ចបរិស្ថានសង្គមល្អ និងធ្វើការស្នើឡើងនូវជម្រើសគោលនយោបាយ និងការប្រតិបត្តិមួយចំនួនសម្រាប់ក្រសួងបរិស្ថាន និងសម្រាប់វិស័យធនាគារក្នុងការធានាឱ្យបាននូវអភិបាលកិច្ចប្រកបដោយចីរភាព។

[1] ក្រុមហ៊ុនស៊ីប៊ីស៊ី (២០១៨). *របាយការណ៍ប្រចាំឆ្នាំ២០១៨*។ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា

[2] ដ-ង-ដ (ដូចឯកសារដើម)

- លើកឡើងនូវបញ្ហាប្រឈម និងឧត្តមានុវត្តន៍របស់ធនាគារ ក្នុងជំរុញនូវការអនុវត្តនូវតម្រូវការនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដល់អតិថិជនរបស់ខ្លួន ក្នុងការទទួលខុសត្រូវសម្រាប់ការប្រតិបត្តិទៅលើអភិបាលកិច្ចបរិស្ថាន-សង្គមប្រកបដោយចីរភាព។
- ធ្វើការផ្សព្វផ្សាយ និងបង្ហាញជូនដល់ភាគីពាក់ព័ន្ធនានារួមទាំងក្រសួងបរិស្ថាន, ធនាគារជាតិនៃកម្ពុជា, សមាគមធនាគារនៅកម្ពុជា នូវអនុសាសន៍សម្រាប់គោលនយោបាយ ក្នុងការជំរុញការវិនិយោគប្រកបដោយសង្គតិភាព និងការទទួលខុសត្រូវខ្ពស់នៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។

## ៣. ការពិភាក្សាលើលទ្ធផលសិក្សា

ក្របខ័ណ្ឌគតិតយុត្តដែលពាក់ព័ន្ធជាមួយការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានដូចជា (១) ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលត្រូវបានអនុម័តនិងដាក់ឱ្យប្រើប្រាស់នៅក្នុងឆ្នាំ១៩៩៦, (២) អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្នាំ ១៩៩៩, (៣) ប្រកាសលេខ ៣៧៦ ប្រក.បស្ថ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងឆ្នាំ២០០៩, (៤) ប្រកាសលេខ០២១ ប្រក.បស្ថ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំ២០២០, និង (៥) អនុក្រឹត្យពាក់ព័ន្ធ[3] ជាមួយនឹងការបំពុល និងការត្រួតពិនិត្យការបំពុល និងប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់នូវគំរូលក្ខខណ្ឌការងារសម្រាប់គម្រោងមួយចំនួន[4]។

នៅក្នុងបរិការណ៍នៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម បទប្បញ្ញត្តិរបស់ប្រទេសកម្ពុជានៅមិនទាន់មានការយកចិត្តទុកដាក់នៅឡើយទេក្នុងការជំរុញការគិតគូរអំពីបញ្ហាបរិស្ថាន និងសង្គម និងកិច្ចការពារធនធានធម្មជាតិនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ បទប្បញ្ញត្តិដែលបានចែង និងដាក់ឱ្យប្រើប្រាស់កន្លងមកនេះ គឺសំដៅសម្រួចកិច្ចការងារបច្ចេកទេស និងកែលម្អប្រសិទ្ធភាពការងារគ្រប់គ្រងលើកិច្ចការវាយតម្លៃហេតុប៉ះពាល់ បរិស្ថាន-សង្គម ដែលមានការណែនាំជាក់លាក់ពីក្រសួងបរិស្ថាន។ មិនមានទេនូវកថាខណ្ឌណាមួយលើកឡើងនូវតម្រុយអំពី ឬស្នើឡើងនូវការដាក់បញ្ចូល ឬបញ្ជ្រៀបការងារវាយតម្លៃនេះទៅក្នុងគោលនយោបាយនិងការប្រតិបត្តិរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ ចំណុចខ្វះខាតនេះ ជាសក្ខីភាពបញ្ជាក់នូវភាពចាំបាច់នាពេលបច្ចុប្បន្ននេះក្នុងការរៀបចំគិតគូរ និងចាប់ផ្តើមការយកចិត្តលើផលប៉ះពាល់បរិស្ថាន សង្គមដែលអាចបង្កឡើងពីការផ្តល់កម្ចី ឬឥណទានដល់គម្រោងអភិវឌ្ឍន៍។ ស្ថានភាពនេះកើតមានដូចគ្នានៅក្នុវិស័យធនាគារ និងហិរញ្ញវត្ថុ ដែលមិនទាន់មានការតម្រូវជាកាតព្វកិច្ចផ្លូវច្បាប់នូវការអនុវត្តកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៅក្នុងការប្រតិបត្តិសេវាធនាគារនិងហិរញ្ញវត្ថុ ជាពិសេសនៅក្នុងការអនុម័តកម្ចី ឬឥណទានដែលអាចនឹងនាំមកនូវហានិភ័យ ទៅលើធនធាន បរិស្ថាន និងសង្គម។

ការអនុវត្តកន្លងមក បានកត់សំគាល់ថាម្ចាស់គម្រោង ឬអតិថិជនដែលបានទទួលកម្ចី ឬឥណទានពីធនាគារអន្តរជាតិ (ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក ឬសារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ) បានខិតខំខ្នះខ្នែងក្នុងការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន-សង្គម ដើម្បីបំពេញតម្រូវការចាំបាច់ជាចំខាត ក្នុងការបង្គ្រប់លក្ខខណ្ឌពេញសិទ្ធិរបស់ធនាគារទាំងនោះ។ តម្រូវការរបស់ធនាគារទាំងនេះ បានឆ្លុះបញ្ចាំងពីការទទួលស្គាល់នូវក្តីព្រួយបារម្ភអំពីបញ្ហាបរិស្ថាន-សង្គម និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពក្នុងរយៈពេលវែង ដែលកំពុងក្លាយជាប្រធានបទយ៉ាងសកម្មនៅក្នុងបរិបទនៃការអភិវឌ្ឍ។ ការផ្តល់កម្ចី ឬឥណទានក្នុងទំហំទឹកប្រាក់ណាមួយនោះ អាចឱ្យអតិថិជន ឬម្ចាស់គម្រោងមានលទ្ធភាពក្នុងការអភិវឌ្ឍ

[3] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹកឆ្នាំ១៩៩៩, អនុក្រឹត្យស្តពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេងឆ្នាំ២០០០, អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ឆ្នាំ២០១៧, អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជនឆ្នាំ២០១៥ ជាដើម។

[4] ដូចជាគម្រោងអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធនិងទេសចរណ៍, វិស័យដំណាំកសិ-ឧស្សាហកម្ម, គម្រោងបង្កើតរោងចក្រនិងសិប្បកម្ម, គម្រោងអាជីវកម្មខ្សាច់សំណង់ និងដីល្បាប់ខ្សាច់, គម្រោងអាជីវកម្មថ្មសម្ភារសំណង់ឆ្នាំ២០១៨។

គម្រោងខ្នាតធំៗមួយចំនួន ដែលអាចបង្កជាហានិភ័យ និងផលប៉ះពាល់ធ្ងន់ធ្ងរទៅលើធនធានបរិស្ថាន និងសង្គមរបស់សហគមន៍ដែលគម្រោងទាំងនោះតាំងនៅ។ ដោយសារហិរញ្ញប្បទានដែលផ្ដល់ឱ្យ អតិថិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំឈូសឆាយ, សាងសង់, ប្រើប្រាស់ធនធាន, និងធ្វើប្រតិបត្តិការលើគម្រោងរបស់ខ្លួនក្នុងទ្រង់ទ្រាយធំដែលអាចបង្កជាផលរំខាន ឬ ប៉ះទង្គិចជាមួយធនធាន និងសកម្មភាពការងារចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋក្នុង និងជុំវិញតំបន់គម្រោង។

ជាមួយនិងបរិការណ៍ ដែលមានការប្រែប្រួលខ្លាំង ហិរញ្ញប្បទានពីធនាគារបានបង្កើននូវសន្ទុះឧស្សាហភាវូបនីយកម្ម, នគរូបនីយកម្ម, កសិកម្ម, និងទេសចរណ៍ជាដើម តាមរយៈគម្រោងអភិវឌ្ឍន៍ដែលពាក់ព័ន្ធ។ សន្ទុះទាំងនោះ បានជំរុញឱ្យមានការប្រែប្រួលដល់ការប្រើប្រាស់ដី និងការតាំងទីលំនៅរបស់មនុស្ស ដោយបង្កើតឱ្យមាននូវឱនភាពបរិមាណ និងគុណភាពទឹកឬដី , ការថមថយនិងបាត់បង់ជីវៈចម្រុះ, ការទន្ទ្រានតំបន់ព្រៃឈើ, កំណើនការបំពុលបរិស្ថាន, និងផលប៉ះពាល់អវិជ្ជមានទៅលើសុខភាពរបស់មនុស្សជាតិ។ ជាការចាំបាច់ណាស់ដែលគ្រឹះស្ថានធនាគារ នៅក្នុងប្រទេសកម្ពុជាគួរចាប់ផ្ដើមស្វែងយល់អំពីផលវិបាកនានាពីកម្ចី ឬឥណទានទៅលើការខូចខាតគុណភាពបរិស្ថាន និងធនធានសង្គមដើម្បីកាត់បន្ថយហានិភ័យដែលអាចនឹងប៉ះពាល់ត្រឡប់ទៅលើអតិថិជន និងគម្រោងអភិវឌ្ឍរបស់ពួកគេ។

ដោយឡែកនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ មិនមានក្រមគតិយុត្តណាមួយលើកឡើងនូវការគិតគូរអំពីការពារធនធានបរិស្ថាន និងសង្គមដែលអាចទទួលរងនូវហានិភ័យពីការប្រតិបត្តិសេវាធនាគារ និងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជានៅឡើយទេ។ លើកលែងតែ *ក្រមស្ដីពីការប្រតិបត្តិសេវាធនាគារ (ឆ្នាំ២០១៥)* ដែលណែនាំឡើងដោយសមាគមធនាគារនៅកម្ពុជា បានសង្កត់ធ្ងន់អំពីលក្ខណវិនិច្ឆ័យក្នុងការផ្ដល់ឥណទានដល់អតិថិជន តាមរយៈគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាព[5]។ ចំណុច ១២.១ បានណែនាំឱ្យធនាគារធ្វើប្រតិបត្តិការដោយប្រុងប្រយ័ត្ន និងហ្មត់ចត់ក្នុងការសិក្សាវាយតម្លៃទៅលើសមត្ថភាពរបស់អតិថិជនក្នុងការទូទាត់សងឥណទានត្រឡប់មកវិញ។ លក្ខណវិនិច្ឆ័យចំនួនប្រាំ[6] ត្រូវបានដាក់ចេញក្នុងការពិនិត្យលើព័ត៌មាន និងទិន្នន័យ ដើម្បីធ្វើការសិក្សាលើលទ្ធភាពក្នុងទូទាត់សងឥណទាន។ ក្រមនេះ ក៏ដូចជាលក្ខណវិនិច្ឆ័យសម្រាប់ការវាយតម្លៃមុនផ្ដល់ឥណទាន មិនបានសង្កត់ធ្ងន់ ឬគិតគូរអំពីបញ្ហាបរិស្ថាន និងសង្គមដែលអាចជះឥទ្ធិពលទៅលើអាជីវកម្មរបស់អតិថិជន ហើយដែលផលប៉ះពាល់ទាំងនេះអាចនឹងប៉ះទង្គិច និងបន្ថយសមត្ថភាពរបស់អតិថិជន ក្នុងការទូទាត់ឥណទានត្រឡប់ទៅ វិញ។ ក្នុង បរិការណ៍នៃការលើកទឹកចិត្តនៅមានកម្រិត, ការប្រកួតប្រជែងទីផ្សារខ្ពស់, និងការយល់ដឹងនៅមានកម្រិតអំពីអត្ថប្រយោជន៍នៃកិច្ចការពារបរិស្ថាន និងសង្គមក្នុងចំណោមបណ្ដាប្រតិបត្តិករសេវាធនាគារ និងហិរញ្ញវត្ថុនិងសាធារណជន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅមិនទាន់បានអនុវត្តនៅឡើយនូវកាតព្វកិច្ចនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់ជាលក្ខខណ្ឌក្នុងអនុម័តកម្ចី។ ឧត្តមានុវត្តន៍អំពីកិច្ចដំណើរការវាយតម្លៃនេះនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុមិនមានទេនៅក្នុងកំឡុងពេលនៃការសិក្សានេះ ដោយសារក្រសួងបរិស្ថាន ក៏ដូចជាធនាគារជាតិនៃ កម្ពុជា មិនទាន់បានកំណត់ជាតម្រូវការផ្នែកគតិយុត្តសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។

## ៤. អនុសាសន៍សំខាន់ៗ៖

- ក្រសួងបរិស្ថានជាមួយនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គួរចាប់ផ្ដើមធ្វើការជជែក និងពិភាក្សា

[5] គោលការណ៍មានចំណុចសំខាន់ៗចំនួន ០២ គឺ សមាគមនឹងធ្វើការវាយតម្លៃ និងគ្រប់គ្រងទៅលើហានិភ័យបរិស្ថានដែលពាក់ព័ន្ធជាមួយបម្រែបម្រួលអាកាសធាតុ, ការបំពុល, ការគ្រប់គ្រងសំណល់ និងការការពារនូវធនធានធម្មជាតិដែលងាយរងគ្រោះ។ សមាគមនឹងធ្វើការវាយតម្លៃ និងគ្រប់គ្រងទៅលើហានិភ័យនានាដែលអាចបង្កជាផលប៉ះពាល់អវិជ្ជមានទៅលើប្រជាពលរដ្ឋជាពិសេសសហគមន៍ជនបទ, កម្មករ, និងជនជាតិដើមភាគតិច, និងមរតកវប្បធម៌រួមមានភាសា វប្បធម៌ ប្រពៃណី និងតំបន់ប្រវត្តិសាស្ត្រផ្សេងៗ។

[6] លក្ខណវិនិច្ឆ័យចំនួនប្រាំរួមមាន (១) ចំណូលនិងការសន្សំហិរញ្ញវត្ថុ, (២) ព័ត៌មាននៃការយល់ដឹងអំពីបញ្ហាហិរញ្ញវត្ថុពីមុនរបស់អតិថិជន, (៣) ព័ត៌មានដែលទទួលបានពីភ្នាក់ងារឥណទានដែលរួមបញ្ចូលទាំងក្រេឌីតប្យូរ៉ូកម្ពុជា, (៤) បច្ចេកទេសសិក្សាក្នុងការវាយតម្លៃឥណទាន (ការដាក់ពិន្ទុ), និង (៥) ប្រាតិភោគដែលត្រូវបានផ្ដល់ឱ្យ (ប្រសិនបើមាន)។

ជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការស្វែងរកនូវដំណោះស្រាយបែបគោលនយោបាយក្នុងការជំរុញនូវការអនុវត្តឱ្យមានតម្រូវការអំពីលក្ខខណ្ឌបរិស្ថាន និងសង្គម សម្រាប់ការផ្តល់កម្ចីហិរញ្ញប្បទានរបស់ធនាគារដល់គម្រោងអភិវឌ្ឍន៍ទាំងឡាយ ដែលស្ថិតនៅក្នុងបញ្ជីឧបសម្ព័ន្ធនៃប្រកាសលេខ ០២១ ប្រ.ក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងអភិវឌ្ឍន៍។ គោលនយោបាយរួមគ្នាដែលជាឧទាហរណ៍សម្រាប់អនុសាសន៍ មានរូបភាពដូចជា *ប្រកាសរួមស្តីពីតម្រូវការរបាយការណ៍វាយតម្លៃវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមសម្រាប់វិស័យធនាគារនៅក្នុងប្រទេសកម្ពុជា* ជាដើម។

- ជាចំណុចចាប់ផ្តើម និងដើម្បីបង្កភាពងាយស្រួល ធនាគារជាតិនៃកម្ពុជា ត្រូវធ្វើការណែនាំជាគោលនយោបាយ (ជាតម្រូវការចាំបាច់) ដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនានាឱ្យធ្វើការអនុវត្តនូវគោលនយោបាយ និងក្រមគតិយុត្តពាក់ព័ន្ធជាមួយកិច្ចការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (ជាពិសេសអនុក្រឹត្យលេខ ៧២, ប្រកាសលេខ ០២១, ០៩២, ១១៦, ១១៨, ១១៩, ១២០, និង៣៧៦) មុនពេលដែលកម្ចី ឬឥណទានត្រូវបានអនុម័ត។ បន្ថែមពីលើនេះ របាយការណ៍អំពីការអនុវត្តនូវកាតព្វកិច្ចនេះ ត្រូវតែធ្វើជូនធនាគារជាតិនៃកម្ពុជា ដើម្បីជាភស្តុតាង និងឯកសារកាលប្បវត្តិ និងសម្រាប់ការត្រួតពិនិត្យតាមដានការប្រតិបត្តិ នៅពេលអនាគត។
- ក្រោមជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូរ ក្រសួងបរិស្ថានដែលមាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាសេនាធិការ ត្រូវរៀបចំជាគោលការណ៍ណែនាំបន្ថែមស្តីពីនីតិវិធី និងបទដ្ឋានស្តង់ដាក្នុងការប្រតិបត្តិតម្រូវការ សម្រាប់ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន-សង្គមដែលអាចយកទៅអនុវត្តជាមួយធនាគារនៅក្នុងប្រទេសកម្ពុជា។ នីតិវិធី និងបទដ្ឋានស្តង់ដានេះរួមមានប្រកាសរួមគ្នា (រវាងក្រសួងបរិស្ថាននិងធនាគារជាតិនៃកម្ពុជា) ស្តីពីតម្រូវការ លើការសិក្សាវាយតម្លៃហេតុប៉ះពាល់ បរិស្ថានសង្គមនៅក្នុងវិស័យធនាគារ, សៀវភៅណែនាំអំពីបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន-សង្គម និងនីតិវិធីនៃការត្រួតពិនិត្យ និងផ្តល់លិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម, ដំណើរការនៃការចូលរួមជាសាធារណៈ នៅក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គម, ការអង្កេតតាមដានបរិស្ថាន, និងទម្រង់កិច្ចការងាររដ្ឋបាលមួយចំនួន (ឧទាហរណ៍ តារាងម៉ាទ្រិកវាយតម្លៃរហ័ស - Rapid Assessment Matric សម្រាប់ការធ្វើចំណាត់ថ្នាក់គម្រោងកម្ចីដែលមានហានិភ័យបរិស្ថាន) ដែលអាចជួយសម្រួលដល់ការប្រតិបត្តិរបស់ធនាគារក្នុងការអនុវត្តតម្រូវការការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមទៅលើកម្ចីដែលផ្តល់ដល់អតិថិជន។
- សម្រាប់គោលដៅការពារបរិស្ថាន និងសង្គមយូរអង្វែង ក្រសួងបរិស្ថាន និងធនាគារជាតិនៃកម្ពុជាគួរធ្វើការណែនាំតាមរយៈគោលនយោបាយ និងឧបករណ៍អនុវត្តមួយចំនួន (ដូចជាគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធ) ឱ្យធនាគារដែលបានផ្តល់កម្ចី បន្តតម្រូវឱ្យម្ចាស់កម្ចីរៀបចំនូវប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) សម្រាប់ស្ថាប័នរបស់ខ្លួនក្នុងការធានាបានថាបញ្ហា ឬហានិភ័យលើបរិស្ថាន និងសង្គមដែលអាចបណ្តាលមកពីការប្រើប្រាស់កម្ចីធនាគារនឹងត្រូវបានបញ្ចៀស កាត់បន្ថយ ឬប៉ះប៉ូវទៅលើការខូចខាតនានាដែលមិនអាចដោះស្រាយបាន។


*ទំនាក់ទំនងព័ត៌មានបន្ថែមតាមរយៈ៖*

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា** (THE NGO FORUM ON CAMBODIA)

ផ្ទះលេខ #៩-១១, ផ្លូវ ៤៧៦, សង្កាត់ទួលទំពូងទី១, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា

ទូរស័ព្ទ៖ ៨៥៥ (0) ២៣ ២១៤ ៤២៩, អ៊ីម៉ែល៖ www.ngoforum.org.kh